01300893

E420/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 07 / 2016
ម៉ោង (Time/Houre): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើបន្ទាន់របស់ ខៀវ សំផន សុំឱ្យផ្តល់ការបំភ្លឺអំពីវិសាលភាពនៃការចោទសំអាតផ្ទៃក្នុង នៅក្នុងសំណុំរឿង ០០២/០២

១. នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណើបន្ទាន់មួយ ដែលបានដាក់ដោយមេធាវីការពារក្តី ខៀវ សំផន សុំឱ្យផ្តល់ការបំភ្លឺអំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងប្រធានបទការបោសសំអាតផ្ទៃក្នុង (ឯកសារ E420 "សំណើសុំ")។ នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តី ខៀវ សំផន បានបញ្ជូនសំណៅជាការជូនដំណឹងក្រៅផ្លូវការនៃសំណើសុំនេះទៅឱ្យភាគីទាំងអស់ (សូមមើលអ៊ីម៉ែលពីក្រុមមេធាវីការពារក្តី ខៀវ សំផន ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦)។ នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងស្តាប់សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នៅក្នុងសវនាការថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគី ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦)។

01300894

២. ការអះអាងជាសំខាន់របស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ចំពោះវិសាលភាពនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងប្រធានបទការបោសសម្អាតផ្ទៃក្នុង គឺត្រូវបានកំរិតត្រឹមអង្គហេតុនានាដែលបានកើតឡើងនៅក្នុងភូមិភាគឧត្តរ ក្នុងឆ្នាំ ១៩៧៦ និង ភូមិភាគបូព៌ា ក្នុងឆ្នាំ ១៩៧៨ ដូចបានកំណត់នៅក្នុងកថាខណ្ឌ ១៩២ ដល់ ២០៣ នៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១ និង ភ្នំក្រោល និង ពាក់ព័ន្ធទៅនឹងអង្គហេតុនានាដែលបានកើតឡើងនៅកំពង់ឆ្នាំង អូរកន្សែង និង ត្រាំកក់ ដូចបានបញ្ជាក់ច្បាស់នៅពេលក្រោយមកទៀតនៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (សំណើសុំ កថាខណ្ឌ ១១-៣៥, ៤៨-៥១)។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានអះអាងថា ដោយសារតែការចោទប្រកាន់ពាក់ព័ន្ធនឹងការបោស-សំអាតផ្ទៃក្នុងដែលបានប្រព្រឹត្តឡើងស្ថិតនៅក្រៅវិសាលភាពដែនដី និង ពេលវេលា ហើយស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ នោះ ភ័ស្តុតាងអំពីការចោទប្រកាន់បែបនេះគួរត្រូវបានដកចេញពីក្នុងសំណុំរឿង ០០២/០២ (សំណើសុំកថាខណ្ឌ ៣៦-៥១)។ មេធាវីការពារក្ដីសម្ដែងក្ដីបារម្ភបន្ថែមទៀតពាក់ព័ន្ធនឹងការផ្ដល់សក្ខីកម្មរបស់សាក្សី 2-TCW-1005, 2-TCCP-236, 2-TCW-917, 2-TCW-976, 2-TCW-829, 2-TCW-1028 និង 2-TCW-850 ដែលត្រូវបានកំណត់ឱ្យចូលមកផ្ដល់សក្ខីកម្មលើប្រធានបទសវនាការអំពីការបោស-សំអាតផ្ទៃក្នុងចាប់ពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ ដោយសំអាងថា ពុំមានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះអាចផ្ដល់សក្ខីកម្មពាក់ព័ន្ធអំពីការបោសសំអាតផ្ទៃក្នុង ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ឡើយ (សំណើសុំ កថាខណ្ឌ ៥២-៦១)។ *សូមមើលផងដែរ* ប្រតិចារិកសវនាការ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ (សេចក្ដីព្រាង) ទំព័រ ៣១-៣២, ៣៥-៣៦, ៤២, ៤៣) (ភាសាអង់គ្លេស)។

៣. មេធាវីការពារក្ដី នួន ជា យល់ស្របជាមួយនឹងសំណើសុំនេះ និង បានអះអាងថា ទោះបីជាវិសាលភាពនៃការបោសសំអាតត្រូវបានកំណត់ត្រឹមភូមិភាគឧត្តរ និង ភូមិភាគបូព៌ានៅក្នុងដីកាដំណោះស្រាយក៏ដោយ ក៏អង្គជំនុំជម្រះទទួលពិនិត្យផងដែរអំពីការបោសសំអាតដែលកើតឡើងនៅក្នុងភូមិភាគដទៃទៀត ដរាបណាការបោសសំអាតនោះមានការជាប់ទាក់ទិននឹងមន្ទីរសន្តិសុខ ស-២១។ មេធាវីការពារក្ដីសង្កត់ធ្ងន់ថា ភ័ស្តុតាងបែបនេះ អាចជាប់ទាក់ទិននឹងទឡ្ហី-ករណ៍របស់ពួកគាត់ដែលថា មានការចាប់ខ្លួនមនុស្ស ដោយសារតែពួកគេគឺជាផ្នែកមួយនៃក្រុមបះបោរដែលរៀបចំធ្វើរដ្ឋប្រហារផ្ដួលរំលំមជ្ឈិមបក្ស (ប្រតិចារិកសវនាការ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ (សេចក្ដីព្រាង) ទំព័រ ៣៧-៣៨)។ សហព្រះរាជអាជ្ញាអះអាងថា

ភ័ស្តុតាងទាំងអស់ដែលពាក់ព័ន្ធនឹងការកើតមានការបោសសំអាតទាំងនោះ ទាក់ទិនមិនត្រឹមតែចំពោះការកំណត់អំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាក់ទិនផងដែរទៅនឹងអត្ថិភាពនៃគោលនយោបាយស្តីអំពីការកំណត់គោលដៅខ្មាំង និង តួនាទីដែលមន្ទីរសន្តិសុខនានា ជាពិសេសមន្ទីរសន្តិសុខ ស-២១ បានអនុវត្តគោលនយោបាយបែបនេះ។ ជាងនេះទៀត សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះបានសន្និដ្ឋានថា សាក្សី 2-TCW-1005 មានការជាប់ពាក់ព័ន្ធ ពីព្រោះគាត់អាចផ្តល់ភ័ស្តុតាងទាក់ទិននឹងលិខិតមួយដែលគាត់ទទួលបានពីសមាជិកមន្ទីរ ៨៧០ កាលពីឆ្នាំ ១៩៧៨ ដែលបញ្ជាឲ្យគាត់បញ្ជូនកម្មាភិបាលពីក្រចេះ ទៅភ្នំពេញ (ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ (សេចក្តីព្រាង) ទំព័រ ៣៩)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា វិសាលភាពនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងប្រធានបទការបោសសំអាតផ្ទៃក្នុងត្រូវបានកំណត់ត្រឹមអង្គហេតុចំនួនពីរ គឺអង្គហេតុដែលកើតឡើងនៅក្នុងភូមិភាគឧត្តរ និង ភូមិភាគបូព៌ា ពាក់ព័ន្ធទៅនឹងការបង្ហាញអត្ថិភាពគោលនយោបាយមួយដែលកំណត់គោលដៅខ្មាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង អង្គហេតុដែលកើតឡើងពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខជាក់លាក់ គឺ ស-២១ ភ្នំក្រោល និងអូរកន្សែង។ ដោយកត់សម្គាល់អំពីការកំណត់វិសាលភាពបែបនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា អង្គជំនុំជម្រះគួរតែស្តាប់ភ័ស្តុតាងពាក់ព័ន្ធនឹងវគ្គសវនាការផ្សេងៗទៀត ដរាបណាភ័ស្តុតាងនោះពាក់ព័ន្ធទៅនឹងការកំណត់អំពីតួនាទីរបស់ជនជាប់ចោទ និង ការចូលរួមរបស់ពួកគេក្នុងគោលនយោបាយនៅក្នុងសហឧក្រិដ្ឋកម្មរួម (ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ (សេចក្តីព្រាង) ទំព័រ ៤០-៤១។

៤. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា វិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ លើការបំបែកកិច្ចដំណើរការនីតិវិធីសវនាការបន្ថែមលើសំណុំរឿង ០០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ (ឯកសារ E301/9/1)។ ឧបសម្ព័ន្ធមួយដែលភ្ជាប់ទៅនឹងសេចក្តីសម្រេចនោះ បង្ហាញអំពីកថាខណ្ឌផ្សេងៗនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២។

៥. បទល្មើសជាក់លាក់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ មានបង្ហាញនៅចុងបញ្ចប់នៃដីកាដំណោះស្រាយ ចាប់ពីកថាខណ្ឌ ១៣៣៥ ពាក់ព័ន្ធទៅនឹង នួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងមិនចាត់ទុកថា "ការបោសសម្អាតផ្ទៃក្នុង" ជាបទល្មើសជាក់លាក់ទេ។

៦. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងទទួលបន្ទុកពិនិត្យទៅលើអង្គហេតុផ្សេងៗពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំដែលត្រូវបានចោទប្រកាន់ថាត្រូវបានបង្កើតឡើង និង អនុវត្តដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងនេះត្រូវបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយដូចតទៅ៖ *"ការអប់រំ 'សមាសភាពមិនល្អ' និង ការកម្ទេច 'ខ្មាំង' ដែលត្រូវបានរកឃើញទាំងនៅក្នុង និង នៅក្រៅបក្ស"* (ឯកសារ D427 កថាខណ្ឌ ១៥៧)។ ដីកាដំណោះស្រាយលើកឡើងថា *"'ការបោសសម្អាត' ផ្ទៃក្នុងបានកើតឡើងជាលំដាប់ស្របតាមការវិវត្តរបស់គោលនយោបាយនេះ"* (ឯកសារ D427 កថាខណ្ឌ ១៩២)។ ដីកាដំណោះស្រាយនៅក្នុងផ្នែកនេះបានបញ្ជាក់អំពី *"ព្រឹត្តិការណ៍បោសសម្អាត"* ចំនួនពីរ៖ ទីមួយ ការបោសសម្អាតនៅភូមិភាគឧត្តរចាស់ និង នៅភូមិភាគឧត្តរថ្មី និង ទីពីរ ការបោសសម្អាតនៅភូមិភាគបូព៌ា។ ប៉ុន្តែ ផ្នែកនេះបានបញ្ជាក់យ៉ាងច្បាស់អំពីទីតាំង និង អង្គភាពផ្សេងៗ នៅខាងក្រៅភូមិភាគឧត្តរចាស់ និង ភូមិភាគឧត្តរថ្មី និង/ឬ ភូមិភាគបូព៌ា។

៧. មេធាវីការពារក្តី ខៀវ សំផន បានលើកទឡ្ហីករណ៍ថា វិសាលភាពដែនដី និង ពេលវេលានៃការបោសសម្អាតផ្ទៃក្នុង ត្រូវបានកំណត់ទៅលើតែព្រឹត្តិការណ៍នៅភូមិភាគឧត្តរក្នុងឆ្នាំ ១៩៧៦ និង នៅភូមិភាគបូព៌ាក្នុងឆ្នាំ ១៩៧៨ តែប៉ុណ្ណោះ។ មេធាវីការពារក្តី ខៀវ សំផន ក៏បានកំណត់មន្ទីរសន្តិសុខភ្នំក្រោល មន្ទីរសន្តិសុខអូរកន្សែង (មន្ទីរសន្តិសុខទាំងពីរនេះស្ថិតនៅភូមិភាគឦសាន) សហករណ៍ត្រាំកក់ (នៅភូមិភាគនិរតី) និង ព្រលានយន្តហោះកំពង់ឆ្នាំង (នៅភូមិភាគបស្ចិម) ថាក៏ពាក់ព័ន្ធទៅនឹងការបោសសម្អាតផ្ទៃក្នុងដែរ។ ការកំណត់ដ៏ចង្អៀតចំពោះដីកាដំណោះស្រាយបែបនេះ មិនស្របទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែលបានកំណត់នៅក្នុងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីសវនាការទេ។ ដីកាដំណោះស្រាយបានកំណត់យ៉ាងច្បាស់អំពីទីតាំង និង អង្គភាពមួយចំនួន ដែលស្ថិតនៅក្រៅភូមិភាគឧត្តរចាស់ និង ឧត្តរថ្មី និង/ឬ ភូមិភាគបូព៌ា ថាស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ដីកា

ដំណោះស្រាយមិនបានកំណត់អំពីវិសាលភាពពេលវេលាដូចដែលបានអះអាងដោយមេធាវីការពារក្ដី ខៀវ សំផន ឡើយ។

៨. នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E315)។ សេចក្ដីសម្រេចនេះបានកំណត់វគ្គនៃសវនាការមួយក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងប្រធានបទ "ឃ. មន្ទីរសន្តិសុខនានា និង ការបោសសម្អាតផ្ទៃក្នុង" ហើយបានបញ្ចូលមន្ទីរសន្តិសុខបី គឺ អូរកន្សែង ភ្នំក្រោល និង ស-២១។ សេចក្ដីសម្រេចនេះមិនបានកែប្រែវិសាលភាពនៃសំណុំរឿង ០០២ ឬ ពិនិត្យទៅលើគោលនយោបាយស្ដីពីការបោសសម្អាតផ្ទៃក្នុងដែលបានលើកឡើងខាងលើចំពោះតែមន្ទីរសន្តិសុខទាំងបីនេះទេ។ ជាឧទាហរណ៍ ភ័ស្ដុតាងដែលពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ត្រូវបានផ្ដល់អាទិភាព ដើម្បីធ្វើឲ្យមានការពិនិត្យភ័ស្ដុតាងរួមគ្នារវាងមន្ទីរសន្តិសុខនេះជាមួយនឹងសហករណ៍ត្រាំកក់។ កថាខណ្ឌ ៧ នៃសេចក្ដីសម្រេចបានបញ្ជាក់យ៉ាងច្បាស់ថា៖

*មិនអាចមានការកំណត់ព្រំដែនឲ្យបានច្បាស់លាស់រវាងអង្គហេតុនានា ដែលនឹងត្រូវបំបែកសម្រាប់សវនាការនេះឡើយ។ ទោះបីជាមានការកំណត់លំដាប់លំដោយក៏ដោយ ក៏វាអាចមានលទ្ធភាពខ្ពស់ដែលថា សាក្សីម្នាក់ដែលត្រូវបានកោះហៅឲ្យមកផ្ដល់សក្ខីកម្មលើអង្គហេតុជាក់លាក់មួយ នឹងផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុមួយ ឬច្រើនផ្សេងទៀត។ ហេតុដូចនេះ ភាគីទាំងអស់គួរតែចាត់ទុកថា លំដាប់លំដោយដែលត្រូវបានកំណត់សម្រាប់សវនាការគឺគ្រាន់ជាការចង្អុលបង្ហាញ ឬការណែនាំអំពីលំដាប់លំដោយដែលអង្គជំនុំជម្រះមានបំណងយកមកប្រើប្រាស់ដើម្បីពិនិត្យទៅលើភ័ស្ដុតាងនៅក្នុងសំណុំរឿងនេះ។ ភាគីទាំងអស់ចាំបាច់ត្រូវបង្ហាញអំពីភាពបត់បែនក្នុងកម្រិតមួយលើបញ្ហានេះ។*

៩. ហេតុដូច្នេះ វិសាលភាពនៃសំណុំរឿង ០០២/០២ នៅដដែល ដូចដែលកំណត់នៅក្នុងសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E301/9/1)។ លំដាប់លំដោយនៃប្រធានបទសវនាការ ឬ កាលវិភាគនៃការស្ដាប់សក្ខីកម្មសាក្សីជាក់លាក់ទៅលើប្រធានបទជាក់លាក់មួយ ជាជាងទៅលើប្រធានបទផ្សេងទៀត មិនមែនជាការកែប្រែវិសាលភាពនៃសំណុំរឿង ០០២/០២ ឡើយ។

១០. អង្គជំនុំជម្រះកត់សម្គាល់ថា ទំនាក់ទំនងរវាងគោលនយោបាយពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ និង បទល្មើសជាក់លាក់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ គឺជាបញ្ហាដែលត្រូវដោះស្រាយនៅពេលរៀបចំធ្វើសាលក្រម។ នេះជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងលើកឡើងទៅលើបញ្ហានេះនៅពេលនេះ ហើយអង្គជំនុំជម្រះកត់សម្គាល់ថា ជាការគួរឲ្យសោកស្ដាយដែលបញ្ហានេះត្រូវបានលើកឡើងនៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី។

១១. សេចក្ដីសម្រេចនេះគឺជាចម្លើយតបរបស់អង្គជំនុំជម្រះទៅនឹងសំណើសុំរបស់ ខៀវ សំផន។